ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ : ១៦០៩ អយក ស.ណ.ន.

# សេចក្ដីណែនាំ
## ស្ដីពី
## បុគ្គលិកអប់រំបង្រៀនអ្នកសិក្សាពិការ

កន្លងមកក្រសួងអប់រំ យុវជន និងកីឡា បានអនុញ្ញាត ឱ្យបុគ្គលិកអប់រំមួយចំនួន ទៅបម្រើការនៅតាមអង្គការផ្សេងៗ ទាក់ទងនិងវិស័យអប់រំ ។ ដើម្បីលើកទឹកចិត្ត និងជំរុញការអប់រំពិសេសសម្រាប់ជនពិការ ឱ្យស្របតាមមាត្រា៣៨ នៃច្បាប់ស្ដីពីការអប់រំ និងអនុវត្តលិខិតលេខ១៩៤៣ អយក.បល ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៣ ស្ដីពីករណីមន្ត្រីរាជការទៅបំរើការនៅតាមអង្គការផ្សេងៗឱ្យមានប្រសិទ្ធភាព ក្រសួង អប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដូចខាងក្រោម÷

១- រក្សាក្របខ័ណ្ឌ និងបៀវត្ស ជូនលោកគ្រូ អ្នកគ្រូ ដែលបង្ហាត់បង្រៀន ដល់អ្នកសិក្សា ដែលខ្វះសរីរាង្គណាមួយ ឬ ខ្វះសមត្ថភាពនៃសរីរាង្គ ឬ មានការប៉ះទង្គិចខាងខួរក្បាលស្មារតី ឬ កាយសម្បទា និងបញ្ញាសម្បទាខ្សោយ ដូចជា : មានចក្ខុវិញ្ញាណខ្សោយ សោតវិញ្ញាណខ្សោយ បាត់បង់អវៈយវៈ មានពិការភាពខាងសតិបញ្ញា ខ្វាក់ ខ្វិន គ ថ្លង់ នៅតាមមជ្ឈមណ្ឌលអប់រំជនពិការ ឬ អង្គការជនពិការណាមួយ ។

២- អង្គការនានាដែលមានតម្រូវការ ឬ លោកគ្រូ អ្នកគ្រូ ដែលមានបំណងចង់បម្រើការងារតាមកន្លែងបណ្ដុះបណ្ដាលជនពិការ ត្រូវដាក់ពាក្យស្នើសុំទៅការិយាល័យអប់រំស្រុក ខ័ណ្ឌ ហើយការិយាល័យអប់រំ យុវជន និងកីឡាស្រុក ខ័ណ្ឌ ត្រូវបញ្ជូនពាក្យស្នើសុំទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្រុង។ មន្ទីរអប់រំ យុវជន



អាស័យដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ៤២៧ ៣៥៦ / ៤២៦ ៩៥១ / ២១២ ៥១២
E-mail: crsmeys@camnet.com.kh / yangyano@camnet.com.kh Web Site: www.moeys.gov.kh

និងកីឡាខេត្ត ក្រុង ត្រូវបញ្ជូនសំណុំលិខិត និងតម្រូវការគ្រូរបស់អង្គការនានា មកក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យ និង សម្រេច ។

៣- ត្រូវរក្សាការតម្លើងថ្នាក់ ឬ ឋានន្តរសក្តិ និងអតីតភាព សម្រាប់សោធននិវត្តន៍នៅអង្គភាពដើម ។

រាល់សេចក្តីណែនាំទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីណែនាំខាងលើត្រូវទុកជានិរាករណ៍ ។

ក្រសួងសង្ឃឹមថា លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទទីស្តីការក្រសួង លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡាគ្រប់ខេត្ត ក្រុង មានភារកិច្ចផ្សព្វផ្សាយ និងអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព ។

ភ្នំពេញ.ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០០៨

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម_សិទ្ធី**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសារធារណៈ

  *"ដើម្បីជ្រាបជាព័ត៌មាន"*

- គ្រប់អង្គភាពក្រោមឱវាទ
- គ្រប់ខេត្ត ក្រុង

  *"ដើម្បីអនុវត្ត"*

- កាលប្បវត្តិ : ឯកសារ នា.បុគ្គលិក